# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរចាំបាច់

## សំរេច

**មាត្រា ១** : ត្រូវបានបង្កើត ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ហៅកាត់ថា " ក.ស.ស.ស " ។

**មាត្រា ២** : សមាសភាពនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៣** : ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានភារកិច្ច ដូចតទៅ ៖

- សិក្សាស្រាវជ្រាវ និងប្រមូលពត៌មានដើម្បីធ្វើការវិភាគ និងវាយតម្លៃអំពីស្ថានភាព និងការវិវត្តន៍លើ វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅព្រះរាជាណាចក្រកម្ពុជា
- វិភាគ និងវាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ច ស្ថានភាពការងារ និងធុរៈកិច្ច សកម្មភាពផលិតកម្ម អាជីវកម្ម សេវាកម្មនានា សមតាសេដ្ឋកិច្ចក្រៅប្រទេស តុល្យភាពថវិកា

- វិភាគ និងវាយតម្លៃអំពីស្ថានភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ លើផ្នែកសំភារៈ និងស្មារតី ស្ថានភាពសង្គមកិច្ច សុខាភិបាល អប់រំ និង វប្បធម៌
- សហការជិតស្និទ្ធក្នុងការផ្លាស់ប្តូរព័ត៌មាន និងបច្ចេកទេសជាមួយក្រសួង ស្ថាប័នជាតិ ផ្នែកឯកជន ឬអង្គការអន្តរជាតិផ្សេងៗលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ធ្វើរបាយការណ៍ វាយតម្លៃ និងផ្តល់យោបល់អំពីស្ថានការកំណត់គោលដៅ ជ្រើសរើសវិធានការ និងរិះរកមធ្យោបាយដោះស្រាយបញ្ហាផ្សេងៗ លើការងារពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ អោយបានឆាប់រហ័សទាន់សភាពការណ៍ និងទៀងទាត់តាមកាលកំណត់ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៤ :** - ក.ស.ស.ស. មានអគ្គលេខាធិការដ្ឋានជាជំនួយការ ហើយមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- អគ្គលេខាធិការដ្ឋាននៃ ក.ស.ស.ស. ដឹកនាំដោយអគ្គលេខាធិការមួយរូប ទទួលបន្ទុកកិច្ចការរដ្ឋបាល ថវិកា និងការរៀបចំឯកសារទូទៅ
- អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់
- អគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក
- ប្រធានផ្នែកជំនាញ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានមន្ត្រីជំនាញមួយចំនួនជាជំនួយការ ។

**មាត្រា ៥ :** ក.ស.ស.ស. ធ្វើការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ឬតាមបញ្ជារបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រធានអាចអញ្ជើញអ្នកមានសមត្ថកិច្ចផ្សេងៗនៃក្រសួង ស្ថាប័ន ចូលមកបំភ្លឺ ចូលរួមកិច្ចប្រជុំការងារ ឬសិក្សាលើឯកសារពាក់ព័ន្ធ ។

ក.ស.ស.ស. មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦ :** អនុក្រឹត្យលេខ ០៥ អនក្រ.តត ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន ពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ